បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 23 ខែ 3 ឆ្នាំ 2000

# មាតិកា

## I– ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១១-០២-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣១ តែងតាំងឯកឧត្តម អ៊ុន សារូ ជាទីប្រឹក្សានៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា | ២៣០ |


## II– រាជរដ្ឋាភិបាល

### ១–អនុក្រឹត្យ


| | | |
|---|---|---|
| ១១-០២-១៩៩៩ | -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពីការបន្ថែមប្រាក់កំរៃគរុកោសល្យ ជូនបុគ្គលិកសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា | ២៣១ |
| ៩-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៣២ |
| ១១-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៣៣ |
| ១៥-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌក្នុងកងកំលាំងនគរបាលជាតិ | ២៣៣ |


## III– ការងារបណ្តាក្រសួង

### ១–ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

#### ប្រកាស


| | | |
|---|---|---|
| ៩-០២-១៩៩៩ | -ប្រកាសលេខ ០៩៧ ប្រក.សហវ.ពន ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៣៤ |


### ២–ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

#### ប្រកាស


| | | |
|---|---|---|
| ១០-០២-១៩៩៩ | -ប្រកាសលេខ ៤៦៩ **MOC/M99** ស្តីពីការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក | ២៣៦ |
| ១២-០២-១៩៩៩ | -ប្រកាសលេខ ៥០០ **MOC/M99** ស្តីពីការបំពេញបន្ថែមគណៈកម្មការគ្រប់គ្រងកូតាសំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុនៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក | ២៤០ |

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

គិរាជកិច្ចការណ៍
...ថ្ងៃ...ខែ...ឆ្នាំ...

១១-០២-១៩៩៩ -ប្រកាសលេខ ១៥១ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ស៊ីង ទិត "ខេមបូឌា" ខូអិលធីឌី តំណាងដោយលោក LAU SI YIN THO MAS សញ្ជាតិចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ២៥១

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស

១២-០២-១៩៩៩ -ប្រកាសលេខ ០៨៤ ប្រក.កសក.ចត ស្តីពីការបង្កើតក្រុមអនុវត្តគំរោងពិសោធន៍នៃការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ២៥៣

## ៥-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

១០-០២-១៩៩៩ -សេចក្តីសំរេចលេខ ០៨១ សសរ. មសរ.ក្រឧ ស្តីពីការបែងចែកនិស្សិតចំនួន ១៩ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស ២៥៥

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣១

យើង

***

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជា ធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម អ៊ិន សារុ ជាទីប្រឹក្សានៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ និងទំនួលអន្តរជាតិ មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

# ១-អនុក្រឹត្យ

## អនុក្រឹត្យលេខ ១១ អនក្រ.បក

## ស្តីពីការបន្ថែមប្រាក់កំរៃគរុកោសល្យ ជូនបុគ្គលិកសិក្សា នៃ ក្រសួងអប់រំយុវជន និង កីឡា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- យោងសេចក្តីជូនដំណឹង ស្តីពីលទ្ធផលនៃសម័យប្រជុំអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩ លេខ ៥៩ សជណសរ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបន្ថែមប្រាក់កំរៃគរុកោសល្យលើប្រាក់កំរៃគរុកោសល្យពីមុន ជូនបុគ្គលិកសិក្សា នៃក្រសួងអប់រំយុវជន និងកីឡា មួយខែ ម្នាក់ ២០.០០០ រៀល ។

**មាត្រា ២ .-** ប្រាក់ឧបត្ថម្ភដែលកំណត់ក្នុងមាត្រា ១ ត្រូវចាប់អនុវត្តន៍ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ តទៅ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៤ ._ អនុក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៤ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងតាមសំណើរបស់ប្រធានមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា

## សំរេច

មាត្រា ១ ._ តែងតាំង :

១-លោក គង់ វដ្ឋា ជាជំនួយការរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន ។

២-លោក ជាតិ តន្ត្រី ជាជំនួយការរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៥ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា ១ ._** ផ្ទាស់លោក មាស គឹមហេង បច្ចុប្បន្ន ទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ឲ្យមកចូលក្នុងប្រទេសវិញ ដោយរក្សាបុព្វហេតុ ។

**មាត្រា ២ ._** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ._** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣៦ អនក្រ.តត
## ស្តីពីការបន្ថែមគ្រូបង្រៀនក្នុងកងកំលាំងនគរបាលជាតិ

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានបន្ថែមក្របខ័ណ្ឌនគរបាលជាតិចំនួន២០០ កន្លែង ( ពីររយកន្លែង ) សំរាប់អធិការដ្ឋាននគរបាលស្រុកអន្លង់វែង ដែលទើបបង្កើតថ្មី ។

**មាត្រា ២ .**_ ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗរបស់កងកំលាំងនគរបាលនេះ ត្រូវបានផ្តល់ជូនចាប់ពីខែកញ្ញា ឆ្នាំ ១៩៩៨ តទៅ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ប្រកាស**

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

**ប្រកាសលេខ ០៩៧ ប្រក.សហវ.ពជ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និង រដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងហិរញ្ញវត្ថុ និងសារាចរណែនាំអនុវត្តលេខ ០៥៧ កហវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩១ របស់ក្រសួងហិរញ្ញវត្ថុ
- បានឃើញ សារាចរលេខ ០១០ សរ/សហវ/គឌ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការពន្ធដារ
- បានពិនិត្យលិខិតស្នើលេខ ១៦៧៤ ខបជ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨ អភិបាលខេត្តបន្ទាយមានជ័យ
- បានឃើញការឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការពន្ធដារ ដូចមានរាយនាមខាងក្រោម :

១-លោក នាក់ សារី ពីអនុប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ ជាប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ

២-លោក សោម ហាក់ ពីប្រធានស្នាក់ការពន្ធដារស្រុកអូរជ្រៅ ជាអនុប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ១៩៩៩

ហត្ថលេខា និងត្រា

គាត ឈន់

## ២-និស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ប្រកាសលេខ ៤៦៩ MOC / M ៩៩

### ស្តីពីការដាក់អោយដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក

***

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០១៩៦/១៦ អនក្រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស , រោមសត្វ សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩
- យោងស្មារតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ៣៦០ MOC/M 99 ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតាសំរាប់ការនាំចេញវាយនភ័ណ្ឌនិងផលិតផលវាយនភ័ណ្ឌដែលជាកម្មវត្ថុនៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក
- បានឃើញការចាំបាច់របស់ក្រសួង

### សំរេច

ប្រការ ១ : គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះឈ្មោះនៅនាយកដ្ឋាន GSP នៃក្រសួងពាណិជ្ជកម្មមុនថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ ត្រូវបានអញ្ជើញអោយមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ Quota ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

ប្រការ ២ : រោងចក្រនីមួយៗត្រូវបានអនុញ្ញាតអោយដេញថ្លៃយកជាអតិបរមាតែ ២០%នៃ Quota ដែលដាក់អោយ ដេញថ្លៃតាមប្រភេទនីមួយៗនៃ Quota ដូចតទៅ :

| ប្រភេទ | បរិមាណដេញថ្លៃ ( DZ) | ប្រភេទ | បរិមាណដេញថ្លៃ ( DZ ) |
|---|---|---|---|
| ៣៣១/៦៣១ | ១១២.០០០ | ៣៤៧/៣៤៨/៦៤៧/៦៤៨ | ២២៩.០០០ |
| ៣៣៤/៦៣៤ | ៨.០០០ | ៣៥២/៦៥២ | ៥៦.០០០ |
| ៣៣៥/៦៣៥ | ២.០០០ | ៤៣៨ | ៣.០០០ |
| ៣៣៨/៣៣៩ | ១០០.០០០ | ៤៤៥/៤៤៦ | ៩.០០០ |
| ៣៤០/៦៤០ | ១២.០០០ | ៦៣៨/៦៣៩ | ៥១.០០០ |
| ៣៤៥ | ៨.០០០ | ៦៤៥/៦៤៦ | ១៤.០០០ |

ប្រការ ៣ : រោងចក្រនីមួយៗអាចដាក់ពាក្យដេញថ្លៃបានច្រើន នូវតំលៃពីរផ្សេងគ្នា សំរាប់ ប្រភេទនីមួយៗ ។

ឧទាហរណ៍ :

បរិមាណសំរាប់ធ្វើការដេញថ្លៃក្នុង Cat ៣៣៨/៣៣៩ មាន ១០០.០០០ ឡ

រោងចក្រ A ដេញថ្លៃ :

២០.០០០ ឡ តំលៃ ៨ ដុល្លារ ក្នុង ១ ឡ

១០.០០០ ឡ តំលៃ ៥ ដុល្លារ ក្នុង ១ ឡ

រោងចក្រ B ដេញថ្លៃ :

៥.០០០ ឡ តំលៃ ១០ ដុល្លារ ក្នុង ១ ឡ

២០.០០០ ឡ តំលៃ ៧ ដុល្លារ ក្នុង ១ ឡ

រោងចក្រ C ដេញថ្លៃ :

១០.០០០ ឡ តំលៃ ៥ ដុល្លារ ក្នុង ១ ឡ

១០.០០០ ឡ តំលៃ ២ ដុល្លារ ក្នុង ១ ឡ

រោងចក្រ D ដេញថ្លៃ :

១០.០០០ ឡ តំលៃ ៤ ដុល្លារ ក្នុង ១ ឡ

១០.០០០ ឡ តំលៃ ២ ដុល្លារ ក្នុង ១ ឡ

រោងចក្រ E ដេញថ្លៃ :

១២.០០០ ឡ តំលៃ ៦ ដុល្លារ ក្នុង ១ ឡ

២០.០០០ ឡ តំលៃ ១ ដុល្លារ ក្នុង ១ ឡ

រោងចក្រ F ដេញថ្លៃ :

១០.០០០ ឡូ តំលៃ ៣ ដុល្លារ ក្នុង ១ ឡូ

២៥.០០០ ឡូ តំលៃ ១ ដុល្លារ ក្នុង ១ ឡូ

លទ្ធផល :

| | |
|---|---|
| រោងចក្រ A ទទួលបាន | ២០.០០០ ឡូ ក្នុងតំលៃ ៨ ដុល្លារ |
| រោងចក្រ B ទទួលបាន | ៥.០០០ ឡូ ក្នុងតំលៃ ១០ ដុល្លារ |
| | ១៥.០០០ ឡូ ក្នុងតំលៃ ៧ ដុល្លារ |
| រោងចក្រ C ទទួលបាន | ១០.០០០ ឡូ ក្នុងតំលៃ ៥ ដុល្លារ |
| | ៩.០០០ ឡូ ក្នុងតំលៃ ២ ដុល្លារ |
| រោងចក្រ D ទទួលបាន | ១០.០០០ ឡូ ក្នុងតំលៃ ៤ ដុល្លារ |
| | ៩.០០០ ឡូ ក្នុងតំលៃ ២ ដុល្លារ |
| រោងចក្រ E ទទួលបាន | ១២.០០០ ឡូ ក្នុងតំលៃ ៦ ដុល្លារ |
| រោងចក្រ F ទទួលបាន | ១០.០០០ ឡូ ក្នុងតំលៃ ៣ ដុល្លារ |

ពាក្យសុំដេញថ្លៃផ្សេងៗទៀតចាត់ទុកជាមិនទទួលបានជោគជ័យ ។

ប្រការ ៤ : ពាក្យសុំដេញថ្លៃនីមួយៗត្រូវភ្ជាប់មកជាមួយ Certified Cheqoe ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានបត្រនេះនឹងត្រូវទូទាត់ប្រាក់ជូនគណៈកម្មការគ្រប់គ្រងកូតានាំចេញ (EQMC) ។ ការបង់មិនគ្រប់ប្រាក់កក់អប្បបរមា ១០% នឹងចាត់ទុកជាពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។

ឧទាហរណ៍ រោងចក្រ A

២០ ០០០ ឡូ តំលៃ ៨ ដុល្លារ / ឡូ = ១៦០.០០០ ដុល្លារ

១០.០០០ ឡូ តំលៃ ៥ ដុល្លារ / ឡូ = ៥០.០០០ ដុល្លារ

**សរុប = ២១០.០០០ ដុល្លារ**

ប្រការ ៥ : ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម Category នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានជោគជ័យរហូតដល់បរិមាណ Quota សរុបត្រូវបានបែងចែកអស់ ។

ប្រការ ៦ : Quota ដែលមិនទាន់បែងចែកនឹងបន្តទុកអោយដេញថ្លៃក្រោយទៀត ។

ប្រការ ៧ : ការដេញថ្លៃនឹងត្រូវកំណត់យកតំលៃគត់ នៃដុល្លារអាមេរិក ហើយមិនត្រូវតិចជាងតំលៃដេញថ្លៃ អប្បបរមាចំពោះ Category នីមួយៗដូចតទៅ :

| | | | |
|---|---|---|---|
| Cat ៣៣១/៦៣១ | 1$/dpr | Cat ៣៤៧/៨-៦៤៧/៤៨ | 2$/doz |
| Cat ៣៣៤/៦៣៤ | 1$doz | Cat ៣៥២/៦៥២ | 1$doz |
| Cat ៣៣៥/៦៣៥ | 1$doz | Cat ៤៣៨ | 2$/doz |
| Cat ៣៣៨/៣៣៩ | 2$doz | Cat ៤៤៥/៦ | 2$/doz |

**Cat ៣៤០/៦៤០** **2$doz** **Cat ៦៣៨/៩** **2$/doz**

**Cat ៣៤៥** **2$doz** **Cat ៦៤៥/៦** **2$/doz**

ប្រការ ៨ : ពាក្យដេញថ្លៃត្រូវដាក់ជូនលោកប្រធានEQMCនៃក្រសួងពាណិជ្ជកម្ម នៅអគារជាន់ទី២ លេខ ២០B វិថីព្រះនរោត្តម ។

ប្រការ ៩ : ការិយាល័យទទួលពាក្យដេញថ្លៃគឺ ចាប់ពីថ្ងៃទី២២ ខែកុម្ភៈ ១៩៩៩ ចាប់ផ្តើមនៅម៉ោង ៨ ព្រឹក ។

ប្រការ ១០ : ការិយាល័យឈប់ទទួលពាក្យដេញថ្លៃគឺនៅ ថ្ងៃទី២៤ ខែកុម្ភៈ ១៩៩៩ វេលាម៉ោង ៥ ល្ងាច ។

ប្រការ ១១ : លទ្ធផលនៃការដេញថ្លៃនឹងត្រូវ ប្រកាសនៅថ្ងៃទី២៦ ខែកុម្ភៈ ១៩៩៩ វេលាម៉ោង ៩ព្រឹក ។

ប្រការ ១២ : អ្នកដេញថ្លៃដែលទទួលជោគជ័យ នឹងអាចអនុវត្តបាននៅថ្ងៃទី០៨ មីនា ១៩៩៩ បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃដែលទទួលបានរួចហើយ ។

ប្រការ ១៣ : អ្នកដេញថ្លៃដែលបានជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយក Quota នេះទេនឹងត្រូវរឹបអូសយកប្រាក់កក់ 10% ហើយបរិមាណ Quota នឹងបន្តទុកអោយអ្នកដេញថ្លៃក្រោយៗទៀត ។

ប្រការ ១៤ : អ្នកដេញថ្លៃណាដែលមិនបានជោគជ័យនឹងត្រូវបានផ្តល់ប្រាក់កក់ ១០ % ជូនវិញភ្លាម ។

ប្រការ ១៥ : Quota ដែលទទួលបានតាមរយៈការដេញថ្លៃ ចាត់ទុកថាជា Quota ចំបង ( Fundamental Quota ) នៅឆ្នាំបន្ទាប់ ។ សុពលភាពនៃ Quota នេះគឺអតិបរមា ៣ឆ្នាំ ដោយយោងតាម កិច្ចព្រមព្រៀងសហរដ្ឋអាមេរិក ។

ប្រការ ១៦ : CAT. ៣៣១/៦៣១ : ត្រូវបានកំរិតអោយចំពោះតែអ្នកផលិតស្រោមដៃ ដែលកំពុងដំណើរការមុនថ្ងៃ០១ មករា ១៩៩៩ ។

ប្រការ ១៧ : លទ្ធភាពនៃការផ្លាស់ប្តូរកូតានឹងត្រូវប្រកាសដោយ EQMC នៅពេលក្រោយ ។

ប្រការ ១៨ : ការសំរេចចិត្តរបស់ EQMC នៅក្នុងដំណាក់កាលនេះជាការសំរេចចុងក្រោយ ។

ប្រការ ១៩ : នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រោងចក្រផលិតការ សំលៀកបំពាក់ និងសមាជិកគណកម្មការគ្រប់គ្រង កូតាសំរាប់នាំចេញត្រូវទទួលអនុវត្តនូវប្រកាសនេះ ។ ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

ចម ប្រសិទ្ធ

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩

**ប្រកាសលេខ ៥០០ MOC / M ៩៩**

**ស្តីពីការបំពេញបន្ថែមគណៈកម្មការគ្រប់គ្រងកូតាសំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌដែលជាកម្មវត្ថុនៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក**

***

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០១៩៦/១៦ អនក្រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស ខ្សៀន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩
- យោងស្មារតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩
- បានឃើញប្រកាសលេខ ៣៦០ ពណ.ប្រក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតាសំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌដែលជាកម្មវត្ថុ នៃការកំណត់បរិមាណដោយសហរដ្ឋអាមេរិក
- បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : បំពេញបន្ថែមគណៈកម្មការគ្រប់គ្រងកូតានាំចេញ ( **EQMC** ) ដែលរួមមានសមាសភាព ដូចតទៅ ៖

| | | | |
|---|---|---|---|
| ១-លោក | សួស សម្បត្តិ | នាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ២-លោក | រស់ សៅ | ជំនួយការរដ្ឋមន្ត្រី | សមាជិក |
| ៣-លោក | ក្រែ ស៊ុនហ្សៀង | ជំនួយការរដ្ឋមន្ត្រី | សមាជិក |
| ៤-លោក | ឈិន ឃឿន | ប្រធានផ្នែករដ្ឋបាល-បច្ចេកទេស | សមាជិក |

៥-លោក ខ៊ិល គូនី មន្ត្រីអគ្គាធិការដ្ឋាន សមាជិក

ប្រការ ២ : នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នាយកដ្ឋានរដ្ឋបាល រាល់ផលិតករសម្លៀកបំពាក់ និងអ្នកដែលមានរាយនាមក្នុងប្រការ ១ ត្រូវទទួលអនុវត្តនូវប្រកាសនេះ ។

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

**ចម ប្រសិទ្ធ**

***

## ៣-ឥស្សិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ប្រកាសលេខ ១៥១ ឧក.ប្រក

***

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តមសីហនុ ព្រះមហាក្សត្រកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៥៩៩/៩៨ គ.វ.ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៥១៦ សអ.ស ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយសាងសង់អាគារកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ីង ថិច ( ខេមបូឌា ) ខូ អិលធីឌី ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩

### សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ស៊ីង ថិច ( ខេមបូឌា ) ខូ អិលធីឌី ( SHING TEX ( CAMBODIA ) Co, LTD ) តំណាងដោយលោក LAU, SI YIN THOMAS សញ្ជាតិ ចិន ( ហុងកុង ) អាយុ

៣៦ ឆ្នាំ អាស័យដ្ឋាន Suite 4005 Gloucester Tower The Landmark HONG KONG កាន់លិខិតឆ្លងដែនលេខ H 00364968 ចុះថ្ងៃទី13-01-1998 បង្កើត “ រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ” ដែលមានឈ្មោះ ថា ” រោងចក្រកាត់ដេរ ស៊ីង ចិច ( ខេមបូឌា ) ” មានទីតាំងនៅអាគារ C8, C9 នៃប្លង់គោលសង់លេខ ៧៥៤រជ/៩៨ ចុះថ្ងៃទី២៦ ខែមីនា ១៩៩៨ ស្ថិតនៅតាមបណ្តោយផ្លូវពីស្ពានិលេវិទ្យុស្ទឹងមានជ័យ ទៅចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ “ កាត់-ដេរ សំលៀកបំពាក់ ” ទៅតាមគំរូដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ “ ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន ស៊ីង ចិច ( ខេមបូឌា ) ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ៤-នីតិការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩

**ប្រកាសលេខ ០៤៤ ប្រក.កសក.ចត**

**ស្តីពីការបង្កើត ក្រុមអនុវត្តគំរោង**

**ពិសោធនៃការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ**

***

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៥ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៣ ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូអោយនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលទ្ធផលនៃការប្រជុំអន្តរក្រសួង នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការគំរោងពិសោធនៃការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតក្រុមអនុវត្តគំរោងពិសោធ នៃការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ក្នុងក្របខ័ណ្ឌមូលនិធិជំនួយរបស់ភ្នាក់ងារបារាំងនៃការអភិវឌ្ឍន៍ ( AFD ) ។ ក្រុមអនុវត្តគំរោងនេះ ស្ថិតក្រោមអាណាព្យាបាលផ្ទាល់ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ប្រការ ២ : ក្រុមអនុវត្តគំរោងពិសោធនៃការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារមានភារកិច្ចដូចតទៅ :

- ទទួលខុសត្រូវចំពោះមុខក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការគ្រប់គ្រងអនុវត្តគំរោងពិសោធនៃការអភិវឌ្ឍន៍ដំណាំកៅស៊ូ ក្នុងក្របខ័ណ្ឌមូលនិធិជំនួយរបស់ភ្នាក់ងារបារាំងនៃការអភិវឌ្ឍន៍។
- សំរបសំរួល និង រៀបចំផែនការ កម្មវិធីអនុវត្តគំរោងសំរាប់ឆ្នាំ ១៩៩៩ និងឆ្នាំបន្តបន្ទាប់ និងគ្រោងថវិកាប្រចាំឆ្នាំ ។
- សហការជ្រើសរើសបុគ្គលិក សំរាប់បំពេញការងារអនុវត្តគំរោង ពីក្របខ័ណ្ឌដែលមានសមត្ថភាពជំនាញបច្ចេកទេសសមស្រប តាមការចាំបាច់ ។
- ផ្សព្វផ្សាយបច្ចេកទេសដល់អ្នកដាំកៅស៊ូ ដោយអ្នកបច្ចេកទេសរបស់ក្រុមអនុវត្តគំរោង
- សិក្សាអំពីស្ថានភាពដី សញ្ញាបត្រទ្រព្យសម្បត្តិរបស់ប្រជាកសិករ ភូមិបាល និង កំណត់លក្ខខណ្ឌក្នុងគ្រួសារសំរាប់ជ្រើសរើសអោយដាំកៅស៊ូ ។
- ផ្តល់ព័ត៌មានដល់កសិករ ស្តីពីគោលដៅនៃគំរោង លក្ខខណ្ឌនិងកិច្ចធានាទៅវិញទៅមក ដើម្បីអោយកសិករមានការយល់ដឹង និងការពិភាក្សាបានត្រឹមត្រូវ ។
- បណ្តុះបណ្តាលអ្នកដាំកៅស៊ូអំពីបច្ចេកទេសដាំកៅស៊ូ និងការធ្វើប្រពលវប្បកម្មដំណាំកសិផលតាមចន្លោះរងកៅស៊ូ
- សំរបសំរួលផ្គត់ផ្គង់ការរៀបចំទាត់ចែងតាមតំបន់សមស្រប នូវកូនកៅស៊ូដែលបានសិក្សាសំរាំងវត្ថុធាតុកសិកម្ម និងការងាររុក្ខារាស់ដោយគ្រឿងយន្តមុនការដាំកូនកៅស៊ូ ។
- អនុវត្ត និង សំរបសំរួលការងារ សំរាប់ជាផលប្រយោជន៍សាធារណៈដូចជា ការរៀបចំធ្វើផ្លូវសំរាប់ចូលទៅកាន់តំបន់អភិវឌ្ឍន៍ដំណាំកៅស៊ូ ដោយចុះកិច្ចសន្យាសាងសង់ជាមួយសហគ្រាសក្នុងស្រុក ឬ ក្រុមហ៊ុនចំការកៅស៊ូ ឧស្សាហកម្មដែលមានទីតាំងនៅជិតការដ្ឋាន និងមានឧបករណ៍គ្រប់គ្រាន់ ហើយនិងប្រគល់ភារកិច្ចទៅអោយសមាគមអ្នកដាំកៅស៊ូ ដើម្បីជួយថែរក្សា និងជួសជុលផ្លូវដែលធ្វើរួចហើយ ។
- ចូលរួមអន្តរាគមន៍ជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធ ដើម្បីអោយទទួលបានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ( ដី ) ដែលត្រូវដាំកៅស៊ូ ។
- រៀបចំបង្កើតសមាគមអ្នកដាំកៅស៊ូ និងកិច្ចដំណើរការរបស់សមាគម ក្នុងការជួយការងារបច្ចេកទេស ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងកៅស៊ូរបស់សមាជិកនីមួយៗ ។
- សំរបសំរួលនិងផ្តល់ឥណទានរយៈពេលខ្លី និងវែង អោយដល់អ្នកដាំកៅស៊ូ តាមរយៈអន្តរការីហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍ជនបទដែលមានឯកទេសគ្រប់គ្រាន់ និង តាមដានការអនុវត្តន៍ ។
- ដឹកនាំនិងគ្រប់គ្រងធ្វើបញ្ជីកា និង គ្រប់គ្រងមូលនិធិជំនួយ ដោយរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពបច្ចេកទេសផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងភ្នាក់ងារបារាំងនៃការអភិវឌ្ឍន៍ ( AFD ) ។
- រៀបចំប្រព័ន្ធតាមដាន វាយតំលៃ តាមផ្នែកនីមួយៗរបស់គំរោង ។

- រៀបចំសៀវភៅបន្ទុក និងដំណើរការលទ្ធកម្មជាលក្ខណៈជាតិ និងអន្តរជាតិតាមគោលការណ៍ ។
- រៀបចំសេចក្តីព្រាងកិច្ចសន្យា ជាមួយអ្នកផ្គត់ផ្គង់ និងអនុសន្និសញ្ញានៃគំរោង ។
- កសាងបទបញ្ជាផ្ទៃក្នុង សំរាប់គ្រប់គ្រងបុគ្គលិក និងរបៀបរបបធ្វើការងារ និងធ្វើកម្មវិធីបណ្តុះបណ្តាល បង្កើនចំណេះដឹងដល់បុគ្គលិក និងអ្នកបច្ចេកទេសបំរើអោយការអនុវត្តន៍គំរោង ។

ប្រការ ៣ : ក្រុមអនុវត្តគំរោងត្រូវដឹកនាំដោយនាយកម្នាក់ និងអ្នកបច្ចេកទេសមួយចំនួនជាជំនួយការ ។

ប្រការ ៤ : ក្រុមអនុវត្តគំរោង មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានចំការកៅស៊ូ សំរាប់ដំណើរការងារជាមួយក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ។

ប្រការ ៥ : អគ្គនាយកក្រសួង នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចាត់តាំង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ឈា សុខ

★★★

## ៥-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ០៩១ សសរ.មស.ក្រខ**
**ស្តីពីការបែងចែកនិស្សិតចំនួន ១៩ នាក់ ដែលទើប**
**បញ្ចប់ការសិក្សាពីបរទេស**

***

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ ខែ_____ ឆ្នាំ_____

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ០១ នាក់ អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១៧ នាក់ និងអ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកឲ្យទៅបំរើការងារ នៅក្រសួង ស្ថាប័នមួយចំនួនដូចខាងក្រោមនេះ :

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ឋានភាព ដើម | មុខជំនាញ បច្ចេកទេស | កំរិតសញ្ញា បត្រ | កំរិត បៀវត្ស | ក្រសួងចូលបំរើ ការងារ | ប្រទេសបញ្ចប់ ការសិក្សា |
|---|---|---|---|---|---|---|---|---|---|
| ១ | ឈឿវ ប៊ុនធឿន | ប | ០៥-០២-៧១ | សិស្ស | សេដ្ឋកិច្ច និងការគ្រប់គ្រងផលិតផលម៉ាស៊ីន | ឧត្តម | ៩០%ខ១១ | ក្រសួងពាណិជ្ជកម្ម | ស្លូវ៉ាគី |
| ២ | ឥន្ទ បញ្ញាធិ | ប | ១៨-៩-៧១ | សិស្ស | បើកបរនាវា | ឧត្តម | ៩០%ខ១១ | ក្រសួងសាធារណការនិងដឹកជញ្ជូន | រុស្ស៊ី |
| ៣ | ពាន់ មុន្នី | ស | ៣-៧-៧៩ | សិស្ស | សំណង់បច្ចេកទេសម៉ាស៊ីន | ឧត្តម | ៩០%ខ១១ | ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | រុស្ស៊ី |
| ៤ | សារិន សៀវហ៊ុង | ប | ១៥-៣-៦២ | សិស្ស | វេជ្ជសាស្ត្រ ទូទៅ | ឧត្តម | ៩០%ខ១១ | ក្រសួងសុខាភិបាល | ឆេកូ |
| ៥ | ប៉ូង ប៊ុន | ប | ១១-៦-៦៩ | សិស្ស | ត្រជាក់ | មធ្យម | ៩០%ខ១១ | ក្រសួងសាធារណការនិងដឹកជញ្ជូន | រុស្ស៊ី |
| ៦ | សយ៉ា តេង | ប | ៣-១២-៧០ | សិស្ស | វេជ្ជសាស្ត្រ | ឧត្តម | ៩០%ខ១១ | ក្រសួងសុខាភិបាល | វៀតណាម |
| ៧ | អ៊ឹម សារិទ្ធ | ប | ២៤-៩-៧២ | សិស្ស | បច្ចេកទេសត្រជាក់ សៀវនិងរោងភ្លើង | ឧត្តម | ៩០%ខ១១ | ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | រុស្ស៊ី |
| ៨ | ស៊ុន សុមេរា | ប | ១២-១០-៧២ | សិស្ស | សេដ្ឋកិច្ច | ឧត្តម | ៩០%ខ១១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អាល្លឺម៉ង់ |
| ៩ | កោះ ភារុណា | ប | ២៧-០១-៧២ | សិស្ស | ការគ្រប់គ្រងហិរញ្ញវត្ថុ | ឧត្តម | ៩០%ខ១១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រុស្ស៊ី |
| ១០ | ហង្ស រ៉ា | ប | ២៧-១២-៦៨ | សិស្ស | សម្ភពនិងរោគស្ត្រី | វេជ្ជបណ្ឌិតឯកទេស | ៩០%ខ១១ | ក្រសួងសុខាភិបាល | រុស្ស៊ី |
| ១១ | សុខ សេរី | ប | ១០-៤-៧៣ | សិស្ស | សេដ្ឋកិច្ចនិងការគ្រប់គ្រងដឹកជញ្ជូនផ្លូវដែក | ឧត្តម | ៩០%ខ១១ | ក្រសួងសាធារណការនិងដឹកជញ្ជូន | រុស្ស៊ី |
| ១២ | ជ័យ បុប្ផា | ស | ២១-៧-៧១ | សិស្ស | វេជ្ជសាស្ត្រ | ឧត្តម | ៩០%ខ១១ | ក្រសួងសុខាភិបាល | វៀតណាម |
| ១៣ | ចន់ ភារម្យ | ស | ២០-៥-៧២ | សិស្ស | ឱសថសាស្ត្រ | ឧត្តម | ៩០%ខ១១ | ក្រសួងសុខាភិបាល | វៀតណាម |
| ១៤ | សេកម សិរីរ័ត្ន | ប | ៧-៨-៦៩ | សិស្ស | វេជ្ជសាស្ត្រទូទៅ | ឧត្តម | ៩០%ខ១១ | ក្រសួងសុខាភិបាល | ស្លូវ៉ាគី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៥ | ម៉ែន ត្រឹទ្ធ | ស | ៧-០១-៦៩ | សិស្ស | វេជ្ជសាស្ត្រទូទៅ | ឧត្តម | ៩០%ខ១ | ក្រសួងសុខាភិ-បាល | ស៊ុយអែត |
| ១៦ | ញ៉ា ម៉ីង | ប | ៧-០២-៧២ | សិស្ស | សំណង់ស៊ីវិល | ឧត្តម | ៩០%ខ១ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ស៊ុយអែត |
| ១៧ | ឈេង ស៊ឹម | ប | ១១-១២-៧២ | សិស្ស | សំណង់ស៊ីវិល | ឧត្តម | ៩០%ខ១ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ស៊ុយអែត |
| ១៨ | ហ៊ែល សារិទ្ធ | ស | ៥-៦-៧០ | សិស្ស | ឱសថសាស្ត្រ | ឧត្តម | ៩០%ខ១ | ក្រសួងសុខាភិ - បាល | ស៊ុយអែត |
| ១៩ | សេង ម៉ូលីណា | ប | ១១-៩-៧៣ | សិស្ស | វេជ្ជសាស្ត្រ | បរិញ្ញា | ៩០%ខ១ | ក្រសួងសុខាភិ - បាល | រុស្ស៊ី |

ប្រការ ២ : ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារ នៅតាមត្រូវការមុខជំនាញ និងផ្តល់ប្រាក់បៀវត្សជូនសាមីជន គាប់ពីថ្ងៃដែលបានចូលបំពេញការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ពេជ្រ ប៊ុនធិន

★★★